**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## ២. សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេច លេខ ២៤ សសរ**

**ស្តីពីការផ្ទេរសិទ្ធិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជារដ្ឋមន្ត្រីស្តីទី ក្រសួងផែនការ ជំនួសឯកឧត្តម **ឆាយ ថន** ដែលត្រូវទៅព្យាបាលជំងឺនៅបរទេស ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០១ រហូតដល់ឯកឧត្តម **ឆាយ ថន** អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

www.pheakdeylaw.com

**ប្រការ ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម **អ៊ឹម ឈុនលឹម** ត្រូវអនុវត្ត សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេច លេខ ២៥ សសរ**

**ស្តីពី**

**ការផ្ទេរសិទ្ធិ**

៚

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ជារដ្ឋមន្ត្រីស្តីទី ក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **ចម ប្រសិទ្ធ** ដែលត្រូវអញ្ជើញទៅបំពេញ បេសកកម្ម នៅបរទេស ចាប់ពីថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០១ រហូតដល់ឯកឧត្តម **ចម ប្រសិទ្ធ** វិលត្រឡប់មកវិញ ។

www.pheakdeylaw.com